ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា



ការសិក្សាស្រាវជ្រាវ

# ខេត្តកំពត ប្រទេសកម្ពុជា

## កត្តាជោគជ័យក្នុងការពង្រីកគម្រោង

### ការគ្រប់គ្រងការអនុវត្តកម្មវិធីទឹកស្អាតនិងអនាម័យ តាមសាលារៀនដោយថ្នាក់ខេត្ត និងថ្នាក់ស្រុក

គម្រោងអនាម័យ
គំរូតាមសាលារៀន

# កុមារអាចអនុវត្តសកម្មភាព អនាម័យគំរូតាមសាលារៀនដោយ ខ្លួនឯងសាលារៀនក្លាយជាកន្លែង ដែលមានផាសុកភាព



## ការនាំយកកម្មវិធីសុខភាពសិក្សា ដើម្បីពង្រីកគម្រោង

បញ្ហាប្រឈមចម្បងនាពេលបច្ចុប្បន្ន គឺថាតើគួរប្រើវិធីសាស្ត្រ និងបទពិសោធន៍ក្នុងការអនុវត្តកម្មវិធីសុខភាពសិក្សាដែលមានស្រាប់បែបណា ដើម្បីពង្រីកវិសាលភាពប្រកបដោយប្រសិទ្ធភាព។ នេះនៅតែជាបញ្ហាគន្លឹះក្នុងវិស័យសុខភាពសិក្សានិងវិស័យទឹកស្អាតនិងអនាម័យតាមសាលារៀន ជាពិសេសនៅតាមបណ្តាប្រទេសដែលមានធនធានតិចតួចបើប្រៀបធៀបទៅនឹងបញ្ហាប្រឈមដែលមានស្រាប់ក្នុងវិស័យនេះ។ ជារឿយៗការអនុវត្តល្អ តែងតែមាន ប៉ុន្តែការជះឥទ្ធិពលនៅមានកម្រិតប្រសិនបើពួកគេមិនអាចឱ្យមាន និរន្តរភាព និងមិនអាចពង្រីកវិសាលភាពតាមរចនាសម្ព័ន្ធរបស់ រាជរដ្ឋាភិបាលដែលមានស្រាប់។ នេះជាហេតុផលដែលការពង្រីក គម្រោងគឺជាអាទិភាពនៅក្នុងរបៀបវារៈ របស់ក្រសួងអប់រំ យុវជន និងកីឡា។ គោលបំណងគឺដើម្បីពង្រឹងសមត្ថភាព ក្នុងការអនុវត្តនូវវិធីសាស្ត្រសាមញ្ញ អាចពង្រីកបាន និងមាននិរន្តរភាពលើកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន ដែលត្រូវបានដាក់បញ្ចូលទៅ ក្នុងកម្មវិធីដែលមានស្រាប់របស់រាជរដ្ឋាភិបាល។




### គម្រោងអនាម័យគំរូតាមសាលារៀន....

- ធ្វើឱ្យប្រសើរឡើងក្នុងការទទួលបាននូវបរិក្ខារលាងសម្អាតដៃ ទឹកស្អាត និងសាប៊ូប្រើប្រាស់
- ជួយជំរុញឱ្យមានការអនុវត្តសុខភាពអនាម័យ ដូចជាការលាងសម្អាតដៃនឹងសាប៊ូជាបុគ្គលនៅពេលសំខាន់ៗ
- គាំទ្រការអនុវត្តកម្មវិធីជាតិទម្លាក់ដង្កូវព្រូន
- ទប់ស្កាត់ការរីករាលដាលនៃជំងឺពុកធ្មេញថ្មី

ការសិក្សាទៅលើសាលារៀនគំរូចំនួន១០ ដែលបានសាកល្បងអនុវត្តគម្រោងអនាម័យគំរូតាមសាលារៀន និងសាលារៀនចំនួន១០ផ្សេងទៀតដែលមិនបានអនុវត្តគម្រោង ដោយធ្វើសំណាកជ្រើសរើសសិស្សថ្នាក់ទី១ ចំនួន៦២៤នាក់ដែលមានអាយុចាប់ពី៦ដល់៧ឆ្នាំដើម្បីពិនិត្យសុខភាព គឺស្មើនឹង៧៧% នៃអត្រាសិស្សដែលបានពិនិត្យកាលពី២ឆ្នាំមុន។

## គម្រោងអនាម័យគំរូតាមសាលារៀនប្រចាំតំបន់

ដោយទទួលស្គាល់ថា ត្រូវតែមានដំណោះស្រាយចំពោះជំងឺដែលបណ្តាលមកពីកង្វះអនាម័យ ដូចជាជំងឺឆ្លងដង្កូវព្រូន ជំងឺរាគ និងជំងឺពុកធ្មេញក្នុងចំណោមសិស្សដែលគ្រប់អាយុចូលរៀនក្នុងតំបន់អាស៊ីអាគ្នេយ៍ គម្រោងអនាម័យគំរូតាមសាលារៀន ត្រូវបានអនុវត្តនៅក្នុងប្រទេសហ្វីលីពីន តាមរយៈក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់។

### វិធីសាស្រ្តគម្រោងអនាម័យគំរូតាមសាលារៀន ផ្តោតលើគោលការណ៍សំខាន់ៗ៤៖

**សាមញ្ញ**
**អាចពង្រីកបាន**
**មាននិរន្តរភាព**
**មានលក្ខណៈជាប្រព័ន្ធ**

គោលបំណង គឺដើម្បីធ្វើឱ្យសាលាបឋមសិក្សាសាធារណៈមានបរិយាកាសសិក្សាគាំទ្រ ដែលកុមារអាចបង្កើត និងអនុវត្តទម្លាប់អនាម័យល្អ អាចរៀនសូត្រ និងលូតលាស់។ គម្រោងនេះលើកកម្ពស់ការប្រើវិធីសាស្រ្តជាជំហានៗ ដើម្បីជួយសាលារៀនធ្វើការកែលម្អទៅតាមធនធាន កាលៈទេសៈ និងសមត្ថភាពរបស់ពួកគេ។ ក្រៅពីកែលម្អបរិយាកាសសិក្សា ការដុសសម្អាតធ្មេញជាមួយថ្នាំដុសធ្មេញដែលមានសារធាតុភ្លុយអរ និងការលាងសម្អាតដៃនឹងសាប៊ូជាក្រុមប្រចាំថ្ងៃ និងការលេបថ្នាំទម្លាក់ដង្កូវព្រូន២ដងក្នុងមួយឆ្នាំ ត្រូវបានអនុវត្តនៅក្នុងសាលារៀន។ ការអនុវត្ត គឺមានលក្ខណៈសាមញ្ញ មានប្រសិទ្ធភាពក្នុងការចំណាយផ្អែកលើភស្តុតាងដែលមានស្រាប់ នឹងអាចពង្រីកបានទោះជាធនធានមានកម្រិតក៏ដោយ។

ប្រទេសកម្ពុជាបានចាប់ផ្តើមអនុវត្តគម្រោងអនាម័យគំរូតាមសាលារៀនតាំងពីឆ្នាំ២០១១មកម្លេះ។ ដោយមានការគាំទ្របច្ចេកទេស ដូចជាការកសាងឯកសារ និងការបំប៉ន សមត្ថភាពពីអង្គការ GIZ និងមជ្ឈមណ្ឌលសម្រាប់គំនិតផ្តួចផ្តើមការអប់រំ និងបច្ចេកវិទ្យាប្រចាំតំបន់ ( SEAMEO INNOTECH ) ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តសាកល្បងកម្មវិធីនេះ នៅសាលារៀនសាធារណៈចំនួន១០ក្នុងភូមិសាស្រ្តខុសៗគ្នា រួមមានរាជធានីភ្នំពេញ និងបណ្តាខេត្ត ដូចជា ខេត្តកំពត តាកែវ កំពង់ធំ និងកំពង់ឆ្នាំង ដោយក្នុងក្រុង ខេត្តនីមួយៗអនុវត្ត២សាលាបឋមសិក្សា។ នៅឆ្នាំ ២០១៤ ក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចផ្តោតលើយុទ្ធសាស្រ្តពង្រីកគម្រោងក្នុងខេត្តកំពតមុនគេ និងបង្កើតការងារជាគំរូសម្រាប់ខេត្តដទៃទៀតក្នុងប្រទេសជាបន្តបន្ទាប់។ មកដល់ខែតុលា ឆ្នាំ២០១៧ ខេត្តកំពតបានពង្រីកគម្រោងអនាម័យគំរូតាមសាលារៀនចំនួន ៧០ សាលាបឋម សិក្សា ( ២៣ % នៃសាលាបឋមសិក្សាសរុបចំនួន៣០៦ ) ក្នុងរយៈពេលតិចជាង២ឆ្នាំ។







## ការសិក្សាពីកត្តាជោគជ័យនៃការពង្រីកកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀនក្នុងខេត្តកំពត

ដើម្បីធ្វើឱ្យមានការយល់ដឹងកាន់តែស៊ីជម្រៅពីវិធីសាស្ត្រពង្រីកគម្រោងអនាម័យគំរូតាមសាលារៀនរបស់ក្រសួងអប់រំ យុវជន និងកីឡា SEAMEO INNOTECH និងអង្គការ GIZ បានធ្វើការសិក្សាលើកត្តាជោគជ័យដែលអាចពង្រីកគម្រោងនេះ។ ក្នុងកំឡុងពេលសិក្សា កត្តាដែលជួយឱ្យខេត្តកំពតអាចពង្រីកគម្រោងអនាម័យគំរូតាមសាលារៀន ត្រូវបានកត់សម្គាល់។ ៦ចំណុចបានបញ្ជាក់ថាជាកត្តាជោគជ័យក្នុងការគ្រប់គ្រងការអនុវត្តកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន នៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ដើម្បីពង្រីកទៅសាលារៀនជាច្រើនទៀត និងធានាគុណភាពនៃការអនុវត្ត។

## កត្តាជោគជ័យក្នុងការអនុវត្តកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន

១ ការដាក់បញ្ចូលកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀនទៅក្នុងដំណើរការដែលមានស្រាប់របស់ក្រសួងអប់រំ យុវជន និងកីឡា

២ ការបង្កើតសូចនាករសម្រាប់ភាពជោគជ័យ ដើម្បីធ្វើការវាស់វែងការប្រឈមនិងគោលដៅ

៣ ការដឹកនាំ៖ ការប្តេជ្ញាចិត្តអាចជំរុញការពង្រីកគម្រោង

៤ ការកសាងសមត្ថភាពមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា ប្រធានកម្រង គណៈគ្រប់គ្រងសាលារៀន គណៈកម្មការសុខភាពសិក្សាសាលារៀន និង គណៈកម្មការទ្រទ្រង់សាលារៀន

៥ ការស្វែងរកការគាំទ្រដ៏រឹងមាំពីគ្រប់អ្នកពាក់ព័ន្ធ ដើម្បីគាំទ្រលើកម្មវិធីទឹកស្អាត និងអនាម័យតាមសាលារៀន

៦ ការយកចិត្តទុកដាក់របស់គណៈគ្រប់គ្រងសាលារៀនអាចទាក់ទាញការចូលរួមពីអ្នកពាក់ព័ន្ធផ្សេងៗ








ក្នុងឆ្នាំ២០១១ គម្រោងអនាម័យគំរូតាមសាលារៀន បានជ្រើសរើសសាលារៀនគំរូចំនួន១០ ក្នុងខេត្តចំនួន៥នៅប្រទេសកម្ពុជាដើម្បីអនុវត្ត ។ សាលារៀនគំរូចំនួន២ស្ថិតក្នុងខេត្តកំពត។ ក្នុងឆ្នាំ២០១៤ ក្រសួងអប់រំ យុវជន និងកីឡា បានជ្រើសយកខេត្តកំពត ដើម្បីពង្រីកគម្រោងអនាម័យគំរូតាមសាលារៀន។ ខេត្តកំពតស្ថិតនៅភាគនិរតីនៃប្រទេសកម្ពុជា ព្រំប្រទល់ជាប់ប្រទេសវៀតណាម ជាមួយឆ្នេរសមុទ្រដ៏វែងជាប់នឹងឈូងសមុទ្រថៃ។ ខេត្តនេះមានក្រុងស្រុកចំនួន៨ រាប់បញ្ចូលទាំងក្រុងកំពត ដែលមានប្រជាជនប្រហែលចំនួន ៦៥០,០០០នាក់ នៅលើផ្ទៃក្រឡា ៤,៨៧៣គីឡូម៉ែត្រការ៉េ។ ខេត្តកំពតបច្ចុប្បន្នមានសាលាបឋមសិក្សាសរុបចំនួន ៣០៦ ដែលមានសិស្សសរុប ៨២,០០០នាក់ និងគ្រូ ២,៩០០នាក់។ ៩១% នៃចំនួនសិស្សទាំងអស់បានបញ្ចប់ការសិក្សានៅថ្នាក់បឋមសិក្សាក្នុងខេត្តកំពត ក្នុងឆ្នាំសិក្សា២០១៥-២០១៦។

កត្តា
ជោគជ័យទី ១

# ការដាក់បញ្ចូលកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន នៅក្នុងដំណើរការចរន្តរបស់ក្រសួងអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត អាចធ្វើឱ្យកម្មវិធីទឹកស្អាតនិងអនាម័យនៅតាមសាលារៀន មានភាពប្រសើរឡើងដោយជោគជ័យនៅតាមស្រុកជាច្រើនក្នុងរយៈពេលខ្លីដោយដាក់បញ្ចូលប្រធានបទទឹកស្អាតនិងអនាម័យក្នុងដំណើរការនិងរចនាសម្ព័ន្ធរបស់ខ្លួន។ មន្ទីរអប់រំ យុវជន និងកីឡាបានលើកទឹកចិត្តដល់មន្ត្រីថ្នាក់ស្រុកឱ្យផ្តោតសំខាន់លើកម្មវិធីទឹកស្អាតនិងអនាម័យនៅពេលត្រួតពិនិត្យការងារបច្ចេកទេសរបស់ពួកគេ។ ឧទាហរណ៍៖ បញ្ជីពិនិត្យតាមដានរបស់សាលាកុមារមេត្រី ដែលបានប្រើសម្រាប់ពិនិត្យតាមដានសាលារៀនបានផ្តោតលើកម្មវិធីទឹកស្អាត និងអនាម័យនៅតាមសាលារៀនក្រោមសមាសភាពទី៣ ស្តីពីសុខភាពសុវត្ថិភាព និងការការពារកុមារ។ មន្ត្រីថ្នាក់ស្រុក និងក្រុមការងារបណ្តុះបណ្តាលនិងពិនិត្យតាមដានថ្នាក់ស្រុក ដែលមានតួនាទីក្នុងរចនាសម្ព័ន្ធគាំទ្រការអនុវត្តគោលនយោបាយសាលាកុមារមេត្រី ប្រើបញ្ជី ពិនិត្យតាមដានដើម្បីលើកកម្ពស់ការយល់ដឹងរបស់នាយកសាលាលើប្រធានបទទឹកស្អាតនិងអនាម័យ អំឡុងពេលពិនិត្យតាមដាន។ ម្យ៉ាងទៀត សាលារៀនដែលបានចាប់ផ្តើម អនុវត្តកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន អាចចែករំលែកបទពិសោធន៍តាមរយៈប្រធានកម្រង ដើម្បីដោះស្រាយបញ្ហាប្រឈមដែលជួបប្រទះ ឬស្វែងរកការប្រឹក្សាសម្រាប់ធ្វើឱ្យប្រសើរឡើងនាពេលអនាគត។



**លោកស្រី ជុំ ភិរុណ ប្រធានគណៈកម្មការសុខភាពសិក្សាក្រុងកំពត** "នៅតាមសាលារៀននីមួយៗ មានរៀបចំគណៈកម្មការសុខភាពសិក្សា ដោយមាននាយកសាលាជាប្រធាន ដើម្បីធ្វើការលើកកម្ពស់ផ្នែកអប់រំសុខភាព។ សាលារៀននីមួយៗ មានកាលវិភាគលាងសម្អាតដៃ ដុសសម្អាតធ្មេញ និងបែងចែកទៅតាមថ្នាក់រៀនគ្រប់កម្រិតថ្នាក់។ ប្រធានកម្រង ទទួលបានការចាត់តាំងពីការិយាល័យអយកស្រុក ដើម្បីលើកកម្ពស់ការយល់ដឹងលើភារកិច្ចដែលដាក់ចេញដោយការិយាល័យអយកស្រុក។ ប្រធានកម្រងក៏ជួយសាលារៀនដែលមិនបានអនុវត្តគម្រោងបានល្អ ឱ្យបានប្រសើរឡើង។ គ្រប់ប្រធានកម្រងប្រជុំប្រចាំខែ រៀងរាល់ថ្ងៃព្រហស្បតិ៍ នៅសប្តាហ៍ទីបួន ដើម្បីជួយគាំទ្រដល់សាលារៀនដែលសមត្ថភាពនៅមានកម្រិត។ បច្ចុប្បន្ននេះ ការលាងសម្អាតដៃ និងដុសសម្អាតធ្មេញជាក្រុមប្រចាំថ្ងៃ ត្រូវបានលើកទឹកចិត្តឱ្យពិភាក្សាអំឡុងពេលប្រជុំ។"

## ការដាក់បញ្ចូលកម្មវិធីទឹកស្អាតនិងអនាម័យទៅក្នុងដំណើរការចរន្តដែលមានស្រាប់ បានផ្តល់នូវផលវិជ្ជមានជាច្រើនដូចជា៖

- ប្រធានបទទឹកស្អាតនិងអនាម័យបានក្លាយជាផ្នែកមួយនៃរបៀបវារៈ នៅពេលសាលារៀនចាប់ផ្តើមពិភាក្សាអំពីបញ្ហា របស់ពួកគេ។
- ការដាក់បញ្ចូលប្រធានបទទឹកស្អាតនិងអនាម័យនៅក្នុងរបៀបវារៈប្រជុំប្រចាំខែ អាចបន្តផ្សារភ្ជាប់ប្រធានបទដូច្នេះ សំណួរដែលចោទម្តងទៀត ( សម្ភារៈប្រើប្រាស់ ឬការបន្តការ អនុវត្តជាប្រចាំ ) អាចត្រូវបានដោះស្រាយដោយវិធីផ្សេងៗទាន់ពេល ហើយអនុសាសន៍ពីថ្នាក់ដឹកនាំ ឬក្រុមការងារអាចកំណត់ជាដំណោះស្រាយចុងក្រោយ។
- ការដាក់បញ្ចូលក្នុងពេលប្រជុំប្រចាំខែ ធ្វើឱ្យមានការចំណាយថវិកាតិចៗ

គ្រប់ខេត្តទាំងអស់សុទ្ធតែមានរចនាសម្ពន្ធ័គណៈកម្មការសុខភាពសិក្សាពីថ្នាក់ខេត្តដល់ថ្នាក់ស្រុក និងតាមសាលារៀន។ ក្នុងខេត្តកំពត រចនាសម្ព័ន្ធគណៈកម្មការសុខភាពសិក្សានេះ បានជួយលើកកម្ពស់ការយល់ដឹងពីបញ្ហាទឹកស្អាតនិងអនាម័យតាមរយៈការជូនដំណឹងដល់ក្រុមការងារ អំពីអត្ថប្រយោជន៍នៃកម្មវិធីទឹកស្អាតនិងអនាម័យ សកម្មភាព និងយុទ្ធសាស្ត្រ និងកៀរគរឱ្យដាក់បញ្ចូលប្រធានបទទឹកស្អាតនិងអនាម័យទៅក្នុងវិស័យការងាររបស់ពួកគេដោយយកចិត្តទុកដាក់បន្ថែម និងចែករំលែកបទពិសោធន៍។

# អនុសាសន៍ ស្តីពីការដាក់បញ្ចូលកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន

## ថ្នាក់ជាតិ

**ក្រសួងអប់រំ យុវជន និងកីឡា**

នាយកដ្ឋានសុខភាពសិក្សា

- ដាក់បញ្ចូលកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន ទៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ
- ស្នើសុំកញ្ចប់ថវិកា សម្រាប់កម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀនក្នុងថវិកាជាតិ

## ថ្នាក់ខេត្ត

**មន្ទីរអប់រំ យុវជន និងកីឡា**

នាយក<br>នាយករង<br>នាយិកា

គណៈកម្មការសុខភាពសិក្សា/សមាជិកពីការិយាល័យចំណុះផ្សេងៗក្នុងមន្ទីរអេយកខេត្ត

- ដាក់បញ្ចូលកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន ក្នុងផែនការប្រតិបត្តិនិងផែនការថវិកាប្រចាំឆ្នាំ
- ដាក់បញ្ចូលកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន ក្នុងកិច្ចប្រជុំគណៈកម្មការសុខភាពសិក្សាប្រចាំខែ
- ដាក់បញ្ចូលកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន ក្នុងកិច្ចប្រជុំជាមួយប្រធានការិយាល័យ អប់រំ យុវជន និងកីឡាក្រុង/ស្រុក
- ដាក់បញ្ចូលកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន ក្នុងកិច្ចប្រជុំជាមួយអភិបាលខេត្ត និងអភិបាលស្រុក
- លើកកម្ពស់ការយល់ដឹងពីកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀនដល់គរុសិស្សនៅតាមសាលាគរុកោសល្យ និងវិក្រិតការខេត្ត
- ស្វែងរកការគាំទ្រពីអ្នកពាក់ព័ន្ធផ្សេងទៀតៗឧទាហរណ៍តាមរយៈ ការចូលរួមប្រជុំ គណៈកម្មការទឹកស្អាតនិងអនាម័យតាមសហគមន៍ សាលារៀនដែលរៀបចំដោយមន្ទីរអភិវឌ្ឍជនបទជារៀងរាល់ត្រីមាស

## ថ្នាក់ស្រុក

**ការិយាល័យអប់រំ យុវជន និងកីឡា**

អនុប្រធាន<br>ការិយាល័យ

គណៈកម្មការសុខភាពសិក្សា/សមាជិក

- យកចិត្តទុកដាក់លើកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន អំឡុងពេលចុះពិនិត្យតាមដាន និងត្រួតពិនិត្យក្នុងសាលារៀន
- បង្កើនការយល់ដឹង ស្តីពីកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន ជាមួយក្រុមការងារបណ្តុះបណ្តាលនិងពិនិត្យតាមដានស្រុក (DTMT)
- បង្កើនការយល់ដឹង ស្តីពីកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន ក្នុងកិច្ចប្រជុំ និងរាយការណ៍ទៅអភិបាលស្រុកប្រចាំខែ
- ដាក់បញ្ចូលកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀនក្នុងកិច្ចប្រជុំគណៈកម្មការសុខភាពសិក្សា
- ដាក់បញ្ចូលកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន ក្នុងកិច្ចប្រជុំជាមួយប្រធានកម្រងប្រចាំខែ និងនាយកសាលារៀន

## ថ្នាក់សាលារៀន

**ប្រធានកម្រង**

នាយក និង<br>ប្រធានកម្រង

គណៈកម្មការសុខភាពសិក្សា/សមាជិក<br>(គ្រូ សិស្ស សហគមន៍)

- លើកឡើងពីសារៈសំខាន់នៃទឹកស្អាតនិងអនាម័យតាមសាលារៀន ក្នុងកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មការសុខភាពសិក្សាជាមួយ លោកគ្រូ អ្នកគ្រូ និងសហគមន៍
- ពិភាក្សា និងចែករំលែកបទពិសោធន៍ពីទឹកស្អាតនិងអនាម័យ តាមសាលារៀន ពេលប្រជុំជាមួយប្រធានកម្រង
- ស្វែងរកមតិគាំទ្រលើកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន តាមរយៈការពិភាក្សាក្នុងកិច្ចប្រជុំប្រចាំខែជាមួយមេឃុំ និងក្រុមប្រឹក្សាឃុំ

កត្តា
ជោគជ័យទី ២

# ការបង្កើតសូចនាករសម្រាប់ភាពជោគជ័យ ដើម្បីធ្វើការវាស់វែងការប្រឈម និងគោលដៅ

ការបង្កើតសូចនាករដើម្បីវាស់ស្ទង់ពីភាពជោគជ័យនៃការពង្រីកគម្រោង ដំណើរការនៅថ្នាក់ក្រោមជាតិគឺថ្នាក់ខេត្តមានជំហររឹងមាំបំផុតក្នុងការប្តេជ្ញាជាមួយថ្នាក់ស្រុកដើម្បីសម្រេចនូវសមិទ្ធផលពិតប្រាកដក្នុងក្របខ័ណ្ឌនៃគោលដៅជាតិ។ យុទ្ធសាស្ត្រដ៏ជោគជ័យមួយរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត គឺលើកទឹកចិត្តការិយាល័យអប់រំ យុវជន និងកីឡាទាំងអស់ កំណត់ចំនួនសាលារៀនជាក់ស្តែងសម្រាប់ពង្រីកកម្មវិធីទឹកស្អាត និងអនាម័យតាមសាលារៀននៅក្នុងបរិបទរបស់ពួកគេផ្ទាល់។ ស្រុកនីមួយៗមានសេរីភាពក្នុងការជ្រើសរើសសាលារៀនតែមួយ ឬពង្រីកសាលារៀន រហូតដល់១០ឬច្រើនជាងនេះក្នុងមួយឆ្នាំ។ អ្វីដែលធ្វើឱ្យខុសប្លែកគ្នាគឺនីតិវិធីនេះបានបង្កើតអារម្មណ៍នៃការប្តេជ្ញាចិត្ត និងការរក្សាពាក្យសន្យា ដែលវានឹងក្លាយជាមោទនភាពមួយប្រសិនបើពួកគេសម្រេចលើសពីគោលដៅ ។

មន្ទីរអប់រំយុវជន និងកីឡាខេត្តទទួលបានជោគជ័យក្នុងការធ្វើឱ្យការិយាល័យអប់រំ យុវជន និងកីឡា និងសាលារៀនគិតថាលទ្ធផលនៃការប្រឹងប្រែងរបស់ពួកគេគឺជាផ្នែកមួយនៃការផ្លាស់ប្តូរច្រើន បើប្រៀបធៀបគោលដៅរបស់ស្រុកនីមួយៗទៅនឹងយុទ្ធសាស្ត្រជាតិនៃការគ្របដណ្តប់ទឹកស្អាតនិងអនាម័យ១០០% ក្នុងប្រទេសកម្ពុជា ដូចដែលបានដាក់ចេញក្នុងផែនការយុទ្ធសាស្ត្រជាតិទឹកស្អាតនិងអនាម័យជនបទ ២០១១-២០២៥។

ទស្សនវិស័យរបស់អ្នកដឹកនាំ ការកំណត់ទិសដៅមានសារៈសំខាន់ណាស់ដើម្បីកែលម្អស្ថានភាពទឹកស្អាត និងអនាម័យ នៅក្នុងខេត្តឬស្រុក ពីព្រោះគោលដៅទាំង នេះតំណាងឱ្យសូចនាករជាក់លាក់។ ចំនួនសាលារៀនដែលបានកំណត់ មិនថាតិចឬច្រើនតំណាងឱ្យគោលបំណងរបស់ស្រុក ឬខេត្ត។ប្រសិនបើថ្នាក់ស្រុកមានផែនការពង្រីកកម្មវិធីទឹកស្អាតនិងអនាម័យនៅក្នុងសាលារៀនចំនួន៨ បន្ថែមទៀត មន្ត្រីការិយាល័យស្រុកមានទឹកចិត្តបង្រៀននិងតាមដានជាប្រចាំជាមួយសាលារៀនទាំងនេះដើម្បីបង្កើនការយល់ដឹងដល់នាយកសាលានិងគ្រូពីសារៈសំខាន់នៃកម្មវិធីទឹកស្អាត និងអនាម័យ។ ថ្នាក់ស្រុក អាចតាមដានវឌ្ឍនភាពបាន។ ប្រសិនបើ បន្ទាប់ពីរយៈពេលជាក់លាក់មួយពួកគេដឹងថាមានតែសាលារៀនតែ២ប៉ុណ្ណោះដែលជោគជ័យ ពួកគេដឹងថា នឹងត្រូវខិតខំបន្ថែមឬស្វែងរកកត្តាដែលរារាំង។ នៅថ្នាក់ខេត្ត អ្នកគ្រប់គ្រងអាចពិនិត្យតាមដានបន្ទាប់ពីពេលវេលាជាក់លាក់មួយ (៦ទៅ១២ខែ) ហើយពិនិត្យឡើងវិញថាតើយ៉ាងហោចណាស់មានសាលារៀនយ៉ាងតិចចំនួន៨បន្ថែមទៀតបានធ្វើឱ្យប្រសើរឡើងដែរឬទេ។ ការកំណត់ទិសដៅមានសារៈសំខាន់ណាស់សម្រាប់វាស់វែងភាពជោគជ័យ ហើយទោះជាមិនអាចសម្រេចបានគ្រប់ចំនួនគោលដៅ អ្នកដឹកនាំគ្រប់លំដាប់ថ្នាក់ត្រូវបានលើកទឹកចិត្តឱ្យចេះវិភាគហេតុផល និងស្វែងរកមធ្យោបាយដើម្បីគាំទ្រការផ្លាស់ប្តូរជាវិជ្ជមាន។

**លោក កៅ រិទ្ធ អនុប្រធានមន្ទីរ អប់រំយុវជន និងកីឡាខេត្តកំពត**

"គោលដៅរបស់រាជរដ្ឋាភិបាល គឺធ្វើឱ្យមានការគ្របដណ្តប់ទឹកស្អាតនិងអនាម័យ ១០០% ក្នុងឆ្នាំ២០២៥។ យើងត្រូវខិតខំប្រឹងប្រែងធ្វើការឱ្យបានសម្រេចទៅតាមគោលដៅរបស់រាជ រដ្ឋាភិបាលបានដាក់ចេញ។ ប៉ុន្តែដើម្បីសម្រេចបានវាជាការទទួលខុសត្រូវនៅក្នុងតំបន់របស់យើងផ្ទាល់។ នៅខេត្តកំពតយើងបានចាប់ផ្តើមដំណើរការកែលម្អស្ថានភាពទឹកស្អាតនិងអនាម័យ ហើយយើងនឹងខិតខំអនុវត្តរួមគ្នាឱ្យបានសម្រេច១០០%នៅចុងឆ្នាំ២០២៥។ សាលារៀនភាគច្រើនដែលនាយក នាយិកា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សយល់ដឹងពីសារៈសំខាន់នៃការងារនេះដើម្បីដើរឱ្យដល់គោលដៅ។"



# ការកំណត់គោលដៅ និងការតាមដាន៖

### មន្ទីរអប់រំ យុវជន និងកីឡា

- កំណត់គោលដៅក្នុងស្រុកឱ្យស្របទៅនឹងសេដ្ឋកិច្ចសង្គមជាក់ស្តែង ដើម្បីសម្រេចគោលដៅជាតិ
- លើកទឹកចិត្តដល់ការិយាល័យស្រុកកំណត់ចំនួនគោលដៅ។ គោលដៅទាំងនេះអាចជាមហិច្ឆតា ប៉ុន្តែពួកគេគួរតែមានភាពប្រាកដនិយម
- ពិនិត្យតាមដានជាទៀងទាត់ ឧទាហរណ៍តាមរយៈ: ការរាយការណ៍នៅក្នុងកិច្ចប្រជុំប្រចាំខែឬនៅក្នុងកិច្ចប្រជុំបូកសរុប ដើម្បីវាយតម្លៃថាតើបន្ទាប់ពីរយៈ ពេលជាក់លាក់ណាមួយ (៦ខែឬ ១ឆ្នាំ) ការិយាល័យ អប់រំ យុវជន និងកីឡាស្រុកបានឈានដល់គោលដៅរបស់ពួកគេដែរឬទេ។

### ការិយាល័យអប់រំ យុវជន និងកីឡា

- កំណត់ចំណាំសាលារៀនគោលដៅដែលមានសក្តានុពល ដែលអាចពង្រីកគម្រោងបានក្នុងរយៈពេលខ្លី។ មន្រ្តីការិយាល័យគួរលើកទឹកចិត្តនាយកសាលាដាក់ផែនការកែលម្អកម្មវិធីទឹកស្អាត និងអនាម័យ!
- ពិភាក្សាជាមួយប្រធានកម្រង៖ តើមានសាលារៀនប៉ុន្មានក្នុងកម្រងរបស់ពួកគេ ដែលពួកគេគិតថាអាចនឹងអនុវត្តកម្មវិធីទឹកស្អាតនិងអនាម័យមានភាពប្រសើរឡើងក្នុងរយៈពេល៦ខែទៀត?
- គួរលើកទឹកចិត្តដល់ប្រធានកម្រងឱ្យកំណត់ចំនួនសាលារៀនគោលដៅ ដើម្បីកែលម្អកម្មវិធីទឹកស្អាត និងអនាម័យ និងតាមដានក្នុងកិច្ចប្រជុំប្រចាំខែ ឧទាហរណ៍តាមរយៈការប្រកួតប្រជែង៖ តើកម្រងណាមួយដែលបានជោគជ័យ១០០% ក្នុងការអនុវត្តលាងសម្អាតដៃជាក្រុមបានមុនគេ?

### សាលារៀនប្រធានកម្រង



កត្តា
ជោគជ័យទី ៣

# ការដឹកនាំ៖ ការប្តេជ្ញាចិត្តអាចជំរុញការពង្រីកគម្រោង

រចនាសម្ព័ន្ធដឹកនាំប្រកបដោយប្រសិទ្ធភាព គឺមានសារៈសំខាន់ណាស់ព្រោះអ្នកដឹកនាំគ្រប់កម្រិតត្រូវមានការសហការយ៉ាងជិតស្និទ្ធ។ ក្នុងខេត្តកំពតមន្ទីរអប់រំ យុវជន និងកីឡាគឺជាអ្នកដឹកនាំសំខាន់ក្នុងដំណើរការពង្រីកគម្រោង។ ដោយមានការប្តេជ្ញាចិត្តរបស់អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា សមត្ថភាពរបស់មន្ត្រីការិយាល័យនិងនាយកសាលារៀន ត្រូវបានពង្រឹងដើម្បីគ្រប់គ្រងនិងអនុវត្តកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន។ អនុប្រធានមន្ទីរមានមោទនៈភាពចំពោះកម្មវិធីនេះដោយសារមានការទទួលស្គាល់៣យ៉ាង៖

១. ការផ្សារភ្ជាប់រវាង គោលនយោបាយនិងកម្មវិធីដែលមានស្រាប់របស់ក្រសួងអប់រំ យុវជន និងកីឡា

២. ការចាត់ទុកជាអាទិភាពរបស់ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចជារដ្ឋមន្ត្រីនិងរដ្ឋលេខាធិការដែលបានគាំទ្រការលាងសម្អាតដៃក្នុងព្រឹត្តិការណ៍សាធារណៈ

៣. លទ្ធផលស្ទង់មតិ ស្តីពីស្ថានភាពសុខភាពកុមារ និងលក្ខខណ្ឌទឹកស្អាតនិងអនាម័យតាមសាលារៀន។

អនុប្រធានមន្ទីរអយក ក្នុងនាមជាប្រធានគណៈកម្មការសុខភាពសិក្សា អាចជ្រើសរើសអ្នកដែលមានសិទ្ធិសម្រេចចិត្តនៅថ្នាក់ស្រុកនីមួយៗ គឺជាប្រធានគណៈកម្មការសុខភាពសិក្សាថ្នាក់ស្រុក។

តាមមធ្យោបាយនេះ ការទទួលខុសត្រូវជារបស់អ្នកធ្វើសេចក្តីសម្រេចចិត្ត នៅរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ខ្ពស់ និងរចនាសម្ព័ន្ធគណៈកម្មការសុខភាពសិក្សាដែលមានស្រាប់ អាចគាំទ្រការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការកែប្រែស្ថានភាពទឹកស្អាតនិងអនាម័យឱ្យកាន់តែប្រសើរឡើង។

ដោយមានការគាំទ្រពីរដ្ឋមន្ត្រី អយក រដ្ឋលេខាធិការ អគ្គនាយកអប់រំ ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងនាយកដ្ឋានសុខភាពសិក្សា បានផ្តល់នូវបរិយាកាសងាយស្រួលតាមរយៈគោលនយោបាយស្តីពីទឹកស្អាតនិងអនាម័យតាមសាលារៀន។ មន្ទីរអប់រំ យុវជន និងកីឡាខេត្តអាចប្រើគោលនយោបាយគាំទ្រនេះដើម្បីពង្រឹងភាពជាអ្នកដឹកនាំក្នុងការអនុវត្ត និងធ្វើឱ្យមានដំណើរការតាមវិធីសាស្ត្ររបស់ពួកគេ។ អ្នកធ្វើការសម្រេចចិត្តនៅថ្នាក់មន្ទីរ អាចចេញសេចក្តីណែនាំស្របតាមគោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមា ស្តីពីទឹកស្អាតនិងអនាម័យតាមសាលារៀន និងណែនាំដល់មន្ត្រីថ្នាក់ស្រុក ឬប្រធានកម្រងដើម្បីបញ្ចូលប្រធានបទទឹកស្អាតនិងអនាម័យតាមសាលារៀនជាទៀងទាត់នៅក្នុងកិច្ចប្រជុំ ក៏ដូចជាលើកទឹកចិត្តឱ្យពួកគេកំណត់គោលដៅច្បាស់លាស់។ ភាពជាអ្នកដឹកនាំដ៏រឹងមាំនៅក្នុងវិស័យអប់រំ ក៏ជាវិធីមួយដ៏មានប្រសិទ្ធភាពក្នុងការតស៊ូមតិជាមួយអ្នកធ្វើការសម្រេចចិត្តនៅថ្នាក់ខេត្ត ឬថ្នាក់ស្រុកដទៃទៀតដូចជា ភិបាល ឬក្រុមប្រឹក្សាស្រុកដើម្បីជួយផ្តល់មូលនិធិ។ មន្ត្រីបច្ចេកទេស ជាពិសេសនាយកសាលា និងលោកគ្រូអ្នកគ្រូនឹងត្រូវបានទទួលការលើកទឹកចិត្តបន្ថែមទៀត ប្រសិនបើពួកគេសង្កេតឃើញថា អ្នកគ្រប់គ្រងរបស់ពួកគេមានការប្តេជ្ញាចិត្តពិតប្រាកដនិងយកចិត្តទុកដាក់អំពីអនាម័យ និងសុខភាព។



**លោក កៅ រិទ្ធ អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត**

"យើងខ្ញុំ ជាអ្នកទទួលខុសត្រូវចំពោះកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន។ ប្រសិនបើយើងមិនមានរចនាសម្ព័ន្ធការងារច្បាស់លាស់នោះទេ ការងារប្រាកដជាមិនអាចរីកចម្រើនទៅមុខទៀតបានឡើយ។ ខ្ញុំបានជ្រើសតាំងប្រធានការិយាល័យបឋមសិក្សាមួយនាក់ និងប្រធានការិយាល័យមធ្យមសិក្សាមួយនាក់ ជាតំណាងរបស់ខ្ញុំដើម្បីជួយគ្នាក្នុងការដឹកនាំ បន្ទាប់មកខ្ញុំបានបង្កើតយន្តការរបៀបនេះនៅថ្នាក់ស្រុក។ ខ្ញុំបានជ្រើសរើសប្រធាន ឬអនុប្រធានការិយាល័យមួយនាក់គ្រប់ស្រុកជាអ្នកទទួលបន្ទុកដឹកនាំការងារសុខភាពសិក្សានៅថ្នាក់ស្រុក ក្រុង និងជាអ្នកបន្តដឹកនាំគ្រប់គ្រងការងារសុខភាពសិក្សាទៅថ្នាក់កម្រង និងសាលារៀនជាបន្តទៀត។ យើងមានការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា ដែលផ្តល់នូវបរិយាកាសងាយស្រួលតាមរយៈគោលនយោបាយ ស្តីពីស្ថានភាពទឹកស្អាតនិងអនាម័យតាមសាលារៀន។ មន្ទីរអប់រំ យុវជន និងកីឡាខេត្តអាចប្រើគោលនយោបាយគាំទ្រនេះដើម្បីពង្រឹងភាពជាអ្នកដឹកនាំក្នុងការអនុវត្ត និងធ្វើឱ្យមានដំណើរការតាមវិធីសាស្ត្ររបស់ពួកគេប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព។"



# រចនាសម្ព័ន្ធគណៈកម្មការសុខភាពសិក្សា

ក្រសួងអប់រំ យុវជន និងកីឡា

នាយកដ្ឋានសុខភាពសិក្សា

របាយការណ៍ទៅ

## គណៈកម្មការសុខភាពសិក្សាថ្នាក់ខេត្ត

| | |
|---|---|
| ប្រធានគណៈកម្មការសុខភាពសិក្សា | អនុប្រធានការិយាល័យ |
| អនុប្រធានគណៈកម្មការសុខភាពសិក្សា | អនុប្រធានគណៈកម្មការសុខភាពសិក្សា |
| ប្រធានការិយាល័យ មធ្យមសិក្សា | ប្រធានការិយាល័យ បឋមសិក្សា |
| សមាជិកគណៈកម្មការសុខភាពសិក្សា | |

ចាត់តាំងប្រធាន គណៈកម្មការ សុខភាពសិក្សា

## គណៈកម្មការសុខភាពសិក្សាថ្នាក់ស្រុក

| | |
|---|---|
| ប្រធានគណៈកម្មការសុខភាពសិក្សា | អនុប្រធានការិយាល័យ |
| អនុប្រធានគណៈកម្មការសុខភាពសិក្សា | ប្រធានការិយាល័យបឋមសិក្សា |
| សមាជិកគណៈកម្មការសុខភាពសិក្សា | |

ទទួលព័ត៌មាន ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យ

## គណៈកម្មការសុខភាពសិក្សាថ្នាក់សាលារៀន

| | |
|---|---|
| ប្រធានគណៈកម្មការសុខភាពសិក្សា | នាយករង |
| អនុប្រធានគណៈកម្មការសុខភាពសិក្សា | ... |
| សមាជិកគណៈកម្មការសុខភាពសិក្សា | |

កត្តាជោគជ័យទី ៤

# ការកសាងសមត្ថភាពមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា ប្រធានកម្រង និងសាលារៀន

មន្ទីរអប់រំ យុវជន និងកីឡាខេត្តជឿថា ការកសាងសមត្ថភាពដល់មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា ប្រធានកម្រង និងសាលារៀន មានសារៈសំខាន់ណាស់សម្រាប់ដំណើរការពង្រីកគម្រោង។ មានន័យថា ពួកគេចាំបាច់អភិវឌ្ឍការយល់ដឹងពីអត្ថប្រយោជន៍នៃការកែលម្អស្ថានភាពទឹកស្អាតនិងអនាម័យតាមសាលារៀន ហើយត្រូវធ្វើបែបណាដើម្បីឱ្យសាលារៀនអាចឈានដល់គោលដៅ។ សំខាន់បំផុតពួកគេក៏ត្រូវការគំរូជាក់ស្តែងពីរបៀបនៃការណែនាំសាលារៀនដើម្បីចាប់ផ្តើមសាកល្បងអនុវត្តឱ្យបានប្រសើរឡើង។ ចំនុចសំខាន់ដែលត្រូវសិក្សាពីការអនុវត្តគម្រោងអនាម័យគំរូអនាម័យតាមសាលារៀន គឺការកសាងសមត្ថភាពដែលមានប្រសិទ្ធភាពត្រូវការយុទ្ធសាស្ត្រច្រើន។ ទាំងនេះរួមបញ្ចូលទាំងវគ្គបណ្តុះបណ្តាល និងបទពិសោធន៍តាមរយៈការផ្លាស់ប្តូរបទពិសោធន៍ ការទស្សនៈកិច្ចសិក្សាដោយផ្ទាល់នៅសាលារៀន និងសម្ភារៈអប់រំផ្សព្វផ្សាយ ដូចជាសៀវភៅណែនាំសម្រាប់សាលារៀននិងសហគមន៍ និងវីដេអូ។

ការប្រើប្រាស់រចនាសម្ព័ន្ធដែលមានស្រាប់ផ្តល់ភាពងាយស្រួលក្នុងការកសាងចំណេះដឹង និងបទពិសោធន៍របស់បុគ្គលិកអប់រំដែលចូលរួម កែលម្អស្ថានភាពទឹកស្អាតនិងអនាម័យ។ គណៈកម្មការសុខភាពសិក្សាថ្នាក់ខេត្តបានប្រើការប្រជុំរបស់ពួកគេ ដើម្បីស្វែងយល់បន្ថែមអំពីសកម្មភាពអនាម័យប្រចាំថ្ងៃ ហើយពួកគេបានរៀនពីសៀវភៅណែនាំសម្រាប់សាលារៀន និងសហគមន៍ ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ស្រុកអំពីខ្លឹមសាររបស់គម្រោង។ ក្នុងសិក្ខាសាលាធ្វើផែនការ ការិយាល័យអប់រំ យុវជន និងកីឡាស្រុកបានកំណត់គោលដៅពង្រីកច្បាស់លាស់សម្រាប់រយៈពេល ៦និង១២ខែ។ នៅថ្នាក់ស្រុក កិច្ចប្រជុំប្រចាំខែ និងប្រជុំគណៈ កម្មការសុខភាពសិក្សា បានចែករំលែកឯកសារបទបង្ហាញខ្លី និងពិភាក្សាពីយុទ្ធសាស្ត្រនិងផែនការ។ ជាការពិតណាស់ សាលារៀនដែលជាប្រធានកម្រងជាមជ្ឈមណ្ឌលចែករំលែកចំណេះដឹង និងបទពិសោធន៍សម្រាប់ការអភិវឌ្ឍថ្មីៗនៃកម្មវិធីទឹកស្អាតនិងអនាម័យ។ នាយកដ្ឋានសុខភាពសិក្សាថ្នាក់ជាតិ ផ្តល់នូវការបណ្តុះបណ្តាល ស្តីពីប្រធានបទជាក់លាក់ និងផ្តល់ការណែនាំអំពីរបៀបបង្កើតយុទ្ធសាស្ត្រកែលម្អ។



**លោក ព្រីង សារុំ អនុប្រធានការិយាល័យយុវជន និងជាសមាជិកគណៈកម្មការសុខភាពសិក្សាខេត្តកំពត**
"សម្ភារៈអប់រំផ្សព្វផ្សាយជាភាសាខ្មែររបស់គម្រោងអនាម័យគំរូតាមសាលារៀន គឺមានអត្ថប្រយោជន៍ណាស់សម្រាប់វគ្គបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ស្រុក និងសាលារៀន។ ការប្រើប្រាស់ភាសាមិនមែនជាបញ្ហាចោទឡើយ ព្រោះវាត្រូវបានរៀបចំឱ្យងាយយល់ ជាពិសេសវីដេអូដែលបង្ហាញពីវិធីសាស្ត្រកែលម្អស្ថានភាពទឹកស្អាតអនាម័យជាជំហានៗ។ ការកសាងសមត្ថភាពរបស់មន្ត្រីថ្នាក់ស្រុក និងនាយកសាលាអាចធ្វើទៅបានតាមរយៈការគាំទ្រយ៉ាងពេញទំហឹងពីនាយកដ្ឋានសុខភាពសិក្សា និងការបង្កើតរចនាសម្ព័ន្ធច្បាស់លាស់នៅគ្រប់កម្រិតទាំងអស់ ដែលធ្វើឱ្យគ្រប់គ្នាងាយស្រួលយល់ពីតួនាទីរបស់ពួកគេ។"

# អនុសាសន៍
# ស្វែងរកវិធីសាស្ត្រថ្មីៗ ដើម្បីកសាងសមត្ថភាព

## ទស្សនៈកិច្ចសិក្សា




- ធ្វើឱ្យមានការសិក្សារៀនសូត្រពីគំរូជាក់ស្តែង ដោយរៀបចំទស្សនៈកិច្ចសិក្សា
- លើកទឹកចិត្តមន្ត្រីថ្នាក់ស្រុក ប្រធានកម្រង និង នាយកសាលា ចែករំលែកបទពិសោធន៍ ភាពជោគជ័យ និងបញ្ហាប្រឈម
- ផ្តោតលើប្រធានបទជាក់លាក់ ដូចជាគុណភាពនៃការអនុវត្តសកម្មភាពប្រចាំថ្ងៃ ឬការកៀរគរថវិកាសម្រាប់សាងសង់កន្លែងលាងសម្អាតដៃជាក្រុម
- អ្នកចូលរួមក្នុងទស្សនៈកិច្ចសិក្សាទទួលបានការបំផុសគំនិតនិងគំនិតថ្មីៗ
- លើកទឹកចិត្តមន្ត្រីថ្នាក់ស្រុករៀបចំ និងដឹកនាំទស្សនៈកិច្ចសិក្សារវាងសាលាកម្រងរបស់ពួកគេ
- ចែករំលែកភាពជោគជ័យ និងការយល់ដឹងតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមដូចជាហ្វេសប៊ុក
- ការបញ្ចូលក្នុងផែនការប្រតិបត្តិការប្រចាំឆ្នាំរបស់ខេត្តដើម្បីបែងចែកថវិកាសម្រាប់ទស្សនៈកិច្ចសិក្សា
- ប្រើកម្រងសំណួរពិនិត្យតាមដាននិងវាយតម្លៃ (គោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមាស្តីពីទឹកស្អាតនិងអនាម័យតាមសាលារៀន ដើម្បីវាស់វែងស្ថានភាពទឹកស្អាតនិងអនាម័យនៅក្នុងសាលារៀន

## ស្នើជំនួយពីអង្គការក្រៅរដ្ឋាភិបាល




- សម្របសម្រួលជាមួយអង្គការក្រៅរដ្ឋាភិបាល ដែលគាំទ្រដល់សាលារៀននៅក្នុងខេត្ត ឬស្រុក
- ស្នើឱ្យពួកគេបណ្តុះបណ្តាលបុគ្គលិកស្រុកអំពីប្រធានបទជាក់លាក់ពាក់ព័ន្ធទៅនឹងទឹកស្អាត និងអនាម័យ
- លើកទឹកចិត្តអង្គការមិនមែនរដ្ឋាភិបាលឱ្យសហការជាមួយបុគ្គលិកអប់រំ ដែលជាអ្នកសម្របសម្រួល និងបង្ហាត់បង្រៀនដល់សាលាដើម្បីពង្រឹងជំនាញសម្របសម្រួល និងតួនាទីរបស់ខ្លួន
- ពិភាក្សាពីតម្រូវការកសាងសមត្ថភាពជាមួយអង្គការក្រៅរដ្ឋាភិបាលនិងលើកទឹកចិត្តពួកគេឱ្យជួយវិនិយោគលើវគ្គបណ្តុះបណ្តាលដែលចាំបាច់
- លើកទឹកចិត្តមន្ត្រីដែលបានបណ្តុះបណ្តាលឱ្យអនុវត្តចំណេះដឹងថ្មីរបស់ពួកគេ ឧទាហរណ៍ដោយការផ្លាស់ប្តូរតួនាទី និងចាត់តាំងជាគ្រូបង្គោលសម្រាប់កម្មវិធីទឹកស្អាតនិងអនាម័យដល់នាយកសាលា

កត្តាជោគជ័យទី ៥

# ការស្វែងរកការគាំទ្រមតិដ៏រឹងមាំពីគ្រប់អ្នកពាក់ព័ន្ធ ដើម្បីគាំទ្រលើកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន

មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានប្រឹងប្រែងស្វែងរកការគាំទ្រមតិ ពីអាជ្ញាធរមូលដ្ឋានគ្រប់កម្រិតដើម្បីឱ្យសាលារៀនអនុវត្តកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀនបានល្អប្រសើរ។ អនុប្រធានមន្ទីរអប់រំផ្តោតសំខាន់ពីសារៈសំខាន់នៃកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន នៅពេលមានការប្រជុំជាមួយអភិបាលខេត្ត។ អភិបាលស្រុក និងសមាជិកក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ បានអញ្ជើញទៅទស្សនៈកិច្ចសិក្សាសាលារៀនដែលអនុវត្តបានល្អ ដើម្បីសិក្សាពីការអនុវត្តទឹកស្អាតនិងអនាម័យ។ មន្ត្រីអប់រំបានរំលឹកពួកគាត់ថា ការផ្តល់មូលនិធិតាមរយៈក្រុមប្រឹក្សា ឧទាហរណ៍ តាមរយៈការគាំទ្រពីគណៈកម្មការទទួលបន្ទុកនារី និងកុមារ អាចជួយដល់សាលារៀនដែលមិនមានថវិកាគ្រប់គ្រាន់ដើម្បីកែលម្អបរិក្ខារអនាម័យឬចំណាយសម្រាប់ការផ្គត់ផ្គង់ដូចជាសាប៊ូ ថ្នាំដុសធ្មេញ ឬសម្ភារៈសម្អាត។ ការិយាល័យអប់រំ យុវជន និងកីឡា បានស្វែងរកមតិគាំទ្រយ៉ាងខ្លាំងនៅសាលារៀន ដើម្បីសាងសង់បរិក្ខារលាងសម្អាតដៃជាក្រុម។ ការគាំទ្រនិងការផ្តល់ដំបូន្មានដល់សាលារៀនត្រូវបានផ្តល់ឱ្យក្នុងអំឡុងពេលកិច្ចប្រជុំថ្នាក់ស្រុក ប្រជុំប្រធានកម្រងជាមួយនាយកសាលា និងការចុះពិនិត្យតាមដាន។ សាលារៀនជាច្រើនបានប្រើប្រាស់មូលនិធិរបស់រដ្ឋាភិបាល(PB) និងឬជំនួយកែលម្អសាលារៀន (SIG) ដើម្បីសង់កន្លែងលាងសម្អាតដៃជាក្រុម។ សាលារៀនផ្សេងទៀតបានស្វែងរកមតិគាំទ្រដោយខ្លួនឯងសម្រាប់កម្មវិធីទឹកស្អាតនិងអនាម័យ ពីអ្នកពាក់ព័ន្ធក្នុងសហគមន៍ដូចជាអាណាព្យាបាលសិស្ស អ្នកមានជីវភាពធូរធារ ឬវត្តអារាម និងអង្គការក្រៅរដ្ឋាភិបាលដែលសកម្មនៅក្នុងសហគមន៍របស់ពួកគេផងដែរ។

**លោក កៅ រិទ្ធ អនុប្រធានមន្ទីរ អប់រំ យុវជន និងកីឡា ខេត្តកំពត**

"ភារកិច្ចរបស់យើងជាមន្ទីរអប់រំ យុវជន និងកីឡាខេត្ត គឺធានាថាលិខិតណែនាំពីអភិបាលខេត្តបានទៅដល់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ដូច្នេះពួកគេអាចធ្វើការដែលជាការងារអាទិភាពដូចគ្នា។ ឃុំមានសារៈសំខាន់ណាស់ព្រោះពួកគេធ្វើការដោយផ្ទាល់ជាមួយសាលារៀន។ ការទទួលខុសត្រូវជាច្រើនត្រូវបានគេធ្វើវិមជ្ឈការទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់។ ដូច្នេះ ក្រុមប្រឹក្សាឃុំសង្កាត់គឺជាគន្លឹះក្នុងការអនុវត្តគម្រោងអនាម័យគំរូតាមសាលារៀន។ ឧទាហរណ៍ អភិបាលរងខេត្តកំពតបានមានប្រសាសន៍ថាក្រុមប្រឹក្សាឃុំ សង្កាត់ គួររួមចំណែកផ្នែកហិរញ្ញវត្ថុក្នុងការអភិវឌ្ឍន៍គម្រោងអនាម័យគំរូតាមសាលារៀន។ រឿងនោះបានកើតឡើងនៅពេលឯកឧត្តមអភិបាលរងខេត្តបានទៅទស្សនៈកិច្ចសិក្សាសាលារៀនមួយនៅក្រុងកំពតដែលគាត់បានឃើញការអនុវត្តល្អៗ ហើយក្រុមប្រឹក្សាឃុំសង្កាត់បានបញ្ជូនសមាជិកឱ្យចូលរួមនៅក្នុងព្រឹត្តិការណ៍នោះដែរ។ នៅប្រទេសយើងប្រសាសន៍ និងតួនាទី របស់អភិបាលមានឥទ្ធិពលខ្លាំង។"





# វិធី៣យ៉ាងសំខាន់ៗសម្រាប់បុគ្គលិកអប់រំថ្នាក់ខេត្ត ឬស្រុកក្នុងការស្វែងរកមតិគាំទ្រលើកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន

១. ស្វែងរកការគាំទ្រមតិ ដោយផ្តោតសំខាន់លើអ្នកនយោបាយ និងអ្នកមានតួនាទី ដូចជាអភិបាលខេត្ត សមាជិកក្រុមប្រឹក្សា គណៈកម្មការ ឬក្រសួងដទៃទៀត។ គោលបំណង គឺលើកកម្ពស់ការយល់ដឹងនិងភាពលេចធ្លោនៃប្រធានបទនេះ ព្រមទាំងដើម្បីបើកទ្វារទទួលបាននូវធនធានបន្ថែមពី រដ្ឋាភិបាល ក្រៅពីក្រសួងអប់រំ យុវជននិងកីឡា។ មន្ទីរអប់រំ យុវជន និងកីឡាបានទាមទារការគាំទ្រមតិជាមួយអភិបាលខេត្ត ដោយដាក់បញ្ចូលកម្មវិធីទឹកស្អាតនិងអនាម័យក្នុងរបាយការណ៍ប្រចាំខែដែលនឹងធ្វើការពិភាក្សានៅក្នុងកិច្ចប្រជុំជាទៀងទាត់។

២. ស្វែងរកការគាំទ្រមតិ ដោយផ្តោតលើសាលារៀនគោលដៅ និងជាពិសេសប្រធានកម្រងបង្កើតប្រធានបទជាអាទិភាពសម្រាប់នាយកសាលា ដើម្បីឱ្យពួកគេបានដឹងលឺថាជាវិធីសាមញ្ញប្រើថវិកាតិច និងមានប្រសិទ្ធភាពដើម្បីលើកកម្ពស់ស្ថានភាពទឹកស្អាតនិងអនាម័យក្នុងសាលារៀនរបស់ពួកគេ។

៣. ស្វែងរកការគាំទ្រមតិក្នុងសហគមន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីមូលហេតុនៃការកែលម្អស្ថានភាពទឹកស្អាតនិងអនាម័យមានសារៈសំខាន់ និងដើម្បីបង្កើនឆន្ទៈរបស់ឪពុកម្តាយឱ្យជួយគាំទ្រ។ ប្រសិនបើសមាជិកសហគមន៍ដទៃទៀត ដូចជាព្រះសង្ឃនៅតាមវត្តអារាម ឬអ្នកមានជីវភាពធូរធារ អាជីវករក្នុងមូលដ្ឋានបានយល់ដឹងពីអត្ថប្រយោជន៍និងយុទ្ធសាស្ត្រដើម្បីសម្រេចឱ្យបាននូវកម្មវិធីទឹកស្អាតនិងអនាម័យកាន់តែប្រសើរ ពួកគេប្រហែលនឹងជួយជាថវិកានិងសម្ភារៈ។

## កត្តាជោគជ័យទី ៦

# ការចូលរួមពីអ្នកពាក់ព័ន្ធយ៉ាងសកម្មលើការងារគ្រប់គ្រងសាលារៀន

ការគ្រប់គ្រងមូលនិធិ ការអនុវត្តកម្មវិធីថ្នាក់ជាតិ ការបង្កើតភាពជាដៃគូ និងទំនាក់ទំនងជាមួយសហគមន៍ដែលមានចំណាប់អារម្មណ៍ចង់ឱ្យសាលារៀន មានដំណើរការល្អ គឺជាធាតុផ្សំសំខាន់នៃការគ្រប់គ្រងតាមសាលារៀន។ ការអនុវត្តគម្រោងអនាម័យគំរូតាមសាលារៀន ជួយអភិវឌ្ឍជំនាញទាំងនេះដោយផ្តោតលើប្រធានបទជាក់លាក់ និងមិនមានភាពចម្រូងចម្រាស់។ មធ្យោបាយដ៏ល្អមួយដើម្បីទទួលការគាំទ្រ គឺជួយគណៈកម្មការទ្រទ្រង់សាលារៀនឱ្យដឹងពីសារៈសំខាន់នៃការលាងសម្អាតដៃជាក្រុមប្រចាំថ្ងៃតាមរយៈទស្សនៈកិច្ចសិក្សា មើលវីដេអូ និងឧទាហរណ៍ជាក់ស្តែង។ ជំហានទាំងនេះអាចរៀបចំដោយមន្ត្រីថ្នាក់ស្រុក ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយប្រធានកម្រង។ មន្ទីរអប់រំ យុវជន និង កីឡាខេត្ត អាចជូនដំណឹងទៅបុគ្គលិកអប់រំ យុវជន និងកីឡាស្រុក អំពីយុទ្ធសាស្ត្រសម្រាប់សាលារៀនទាក់ទងជាមួយសហគមន៍។ ក្រោមការណែនាំរបស់មន្ត្រីអប់រំ យុវជន និង កីឡាស្រុក នាយកសាលា និងគ្រូអាចអនុវត្តជំហានចាំបាច់ដើម្បីសហការជាមួយសហគមន៍ឱ្យកាន់តែមានប្រសិទ្ធភាព។

ក្នុងនាមជានាយកសាលា ការសហការយ៉ាងជិតស្និទ្ធជាមួយសមាជិកគណៈកម្មការទ្រទ្រង់សាលាដែលមានទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំ សង្កាត់អាចជួយដល់ការកៀរគរធន ធាន។ ព្រះសង្ឃជាញឹកញាប់ក៏ជាផ្នែកមួយនៃគណៈកម្មការទ្រទ្រង់សាលាផងដែរ ជាពិសេសវត្តដែលនៅជិតសាលារៀន ការស្វែងរកការគាំទ្រមតិពីព្រះសង្ឃ គឺជាយុទ្ធសាស្ត្រប្រកបដោយផ្លែផ្កាសម្រាប់សាលាជាច្រើន។ វត្តអារាមអាចជួយផ្គត់ផ្គង់ទឹកដល់សាលារៀន និងបរិច្ចាកសម្ភារៈអនាម័យ ដែលពុទ្ធបរិស័ទប្រគេន ហើយវត្តបានអនុញ្ញាតឱ្យដាក់ហិបបរិច្ចាកក្នុងព្រះវិហារសម្រាប់កម្មវិធីទឹកស្អាតនិងអនាម័យក្នុងកម្មពិធីបុណ្យសាសនាផ្សេងៗ។ ពិតណាស់ឪពុកម្តាយឬអាណាព្យាបាលសិស្សតែងចាប់អារម្មណ៍ និងយកចិត្តទុកដាក់បំផុត ក្នុងការចង់ឱ្យសាលារៀនផ្តល់សេវាកម្ម និងបរិយាកាសសិក្សាល្អសម្រាប់កូនៗរបស់ពួកគាត់។ ក្រៅពីបដិភាគជាថវិកា ឬសម្ភារៈ ការចូលរួមរបស់ឪពុកម្តាយជាកម្លាំងពលកម្មសាងសាងសង់សម្អាតថែទាំ ពិសេសការជួសជុល ពិតជាសំខាន់ណាស់ព្រោះវាអាចធានាថានឹងមានការគាំទ្រជាបន្តបន្ទាប់។



**លោកគ្រូ សុខ វណ្ណឌី នាយកសាលាបឋមសិក្សាអង្គថៅពញ្ញានៅស្រុកឈូក**

"ខ្ញុំបានទៅប្រជុំនៅការិយាល័យអប់រំ យុវជន និងកីឡា ដែលប្រធានគណៈកម្មការសុខភាពសិក្សាបានបង្ហាញវីដេអូស្តីពីគម្រោងអនាម័យគំរូតាមសាលារៀន។ ខ្ញុំចាប់ផ្តើមចាប់អារម្មណ៍យ៉ាងខ្លាំង។ ដូច្នេះខ្ញុំបានត្រឡប់មកវិញហើយបានអញ្ជើញសហគមន៍ និងព្រះចៅអធិការវត្ត និងបង្ហាញវីដេអូទាំងនោះទៅពួកគាត់។ យើងបានយល់ព្រមរកថវិកាក្នុងពិធីបុណ្យពូនភ្នំស្រូវ។ ប្រជាជនដែលបានមកចូលរួមក្នុងពិធីនេះបានយកស្រូវ ហើយយើងបានស្នើសុំការចូលរួមបដិភាគជាថវិកា។ យើងអាចរកថវិកាបាន ៩០០,០០០រៀល។ ថវិកាមួយចំនួន យើងបានប្រគេនដល់ព្រះសង្ឃ និងវត្តសម្រាប់ការចំណាយផ្សេងៗ។ ថវិកាដែលនៅសល់ចំនួន ៧០០,០០០រៀល យើងបានចាប់ផ្តើមសាងសង់បរិក្ខារលាងសម្អាតដៃជាក្រុម។ ខ្ញុំអាចរកបានពលកម្មដែលមានតំលៃសមរម្យ ហើយក្នុងអំឡុងពេលសម្រាកអាហារថ្ងៃត្រង់ ខ្ញុំបានចូលរួមសាងសង់ជាមួយពួកគេ។ នេះហើយជាមូលហេតុដែលជាងសំណង់យកពីសាលារៀនតែ ២០០,០០០រៀលប៉ុណ្ណោះ។ នៅពេលដែលយើងអស់ថវិកា យើងបានសុំឱ្យសិស្សចូលរួមបដិភាគជាថវិកាខ្លះ ដែលពេលប្រមូលនេះបានចំនួន ៩០,០០០រៀល ហើយឪពុកម្តាយក៏បានបរិច្ចាកស៊ីម៉ង់ និងខ្សាច់ផងដែរ។ នៅពេលជួបអតីតសិស្សរបស់ខ្ញុំ ខ្ញុំក៏បានសុំឱ្យពួកគេចូលរួមបដិភាគជាថវិកាដើម្បីធ្វើឱ្យសិស្សមានសុខភាពល្អ។ ពួកគេមួយចំនួនក៏បានជួយលើការសាងសាងសង់ផងដែរ។"



# ការសិក្សា ស្ដីពីអ្នកជោគជ័យក្នុងការភៀសរំអនាធិបតេយ្យ

គម្រោងអនាម័យគំរូ
តាមសាលារៀន

នាយកសាលារៀនចំនួន២៨
មកពីស្រុកអង្គរជ័យ
និងក្រុងកំពត

នៅខែកុម្ភៈ ឆ្នាំ២០១៦ គម្រោងអនាម័យគំរូតាមសាលារៀន បានធ្វើបទសម្ភាសន៍ជាមួយនាយកសាលារៀន ចំនួន២៨ មកពីស្រុកអង្គរជ័យនិងក្រុងកំពត ដែលកាលពីមុន សាលារៀនទាំងនេះបានទទួលបរិក្ខារលាងសម្អាតដៃ តែសាលារៀនត្រូវទទួលខុសត្រូវរៀបចំដំឡើង និងរចនាបន្ថែមដោយខ្លួនឯង និងសហគមន៍តាមរយៈការគាំទ្រពីអង្គការ GIZ និងអង្គការ UNICEF។ សាលារៀនទាំងនេះបានចំណាយថវិកាបន្ថែមដើម្បីរចនាបរិក្ខារលាងសម្អាតដៃជាក្រុម ដែលថវិកាបានបដិភាគដោយសហគមន៍។ ការសម្ភាសន៍បានបង្ហាញឱ្យឃើញលទ្ធផលដូចនៅខាងក្រោម៖



## បរិយាកាសគាំទ្រដើម្បីឱ្យសាលារៀនអនុវត្តទទួលបានជោគជ័យ

ការកៀរគរបដិភាគ អាចធ្វើទៅបាននៅក្នុងស្រុកដែលមានបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចផងដែរ

សាលារៀនដែលមិនមានការផ្គត់ផ្គង់ប្រព័ន្ធទឹក ក៏អាចទទួលបានជោគជ័យក្នុងការស្វែងរកបដិភាគសម្រាប់សកម្មភាពអនាម័យ

ការទំនាក់ទំនងយ៉ាងរឹងមាំជាមួយគណៈកម្មការទ្រទ្រង់សាលារៀន និងដល់ព្រះសង្ឃនៅក្នុងវត្ត

ជំរុញការមានទំនាក់ទំនងយ៉ាងរឹងមាំជាមួយការិយាល័យអប់រំ យុវជន និងកីឡាស្រុក

អាណត្តិរបស់គណៈកម្មការទទួលបន្ទុកនារី និងកុមារនៃក្រុមប្រឹក្សាឃុំគឺដើម្បីផ្តល់ការគាំទ្រដល់សាលារៀន ប៉ុន្តែជារឿយៗនាយកមិនបានដឹងពីរឿងនេះ។

## ការទទួលបានជោគជ័យលើការគ្រប់គ្រងបដិភាគថវិកា

រៀបចំទស្សនៈកិច្ចសិក្សារវាងការិយាល័យអប់រំយុវជន និងកីឡាជាមួយនាយកសាលា គ្រូ និងឪពុកម្តាយសិស្សជាពិសេសជាមួយអង្គការសង្គមស៊ីវិល។ ពួកគេប្រើសៀវភៅណែនាំរបស់គម្រោងអនាម័យគំរូតាមសាលារៀន ដើម្បីបង្ហាញពីអត្ថប្រយោជន៍នៃសកម្មភាពអនាម័យជាក្រុម

ទំនាក់ទំនងជាមួយគណៈកម្មការទ្រទ្រង់សាលារៀន។ គណៈកម្មការទ្រទ្រង់សាលា ផ្សាភ្ជាប់សាលារៀន និងភូមិព្រមទាំងរៀបចំសកម្មភាពកៀរគរថវិកា។ គោលបំណងចម្បង និងការលើកទឹកចិត្តសម្រាប់គណៈកម្មការទ្រទ្រង់សាលា គឺត្រូវមានសាលារៀនសម្រាប់កូនៗរបស់ពួកគេអាចរៀនសូត្រនិងត្រៀម ខ្លួនសម្រាប់ជីវិត។ សុខភាពល្អគឺជាលក្ខខណ្ឌសំខាន់មុនគេបង្អស់សម្រាប់ការអប់រំល្អ

ទំនាក់ទំនងជាមួយព្រះសង្ឃ។ ព្រះសង្ឃអាចជាអ្នករៀបចំកម្មវិធីកៀរគរបដិភាគ ទាក់ទងជាមួយម្ចាស់ជំនួយដោយផ្ទាល់ (ថវិកា និងសម្ភារៈផ្សេងៗ) និងជាអ្នកសម្របសម្រួលរវាងសាលារៀន និងភូមិ

មានតម្លាភាព និងគណនេយ្យភាពចំពោះអ្នកពាក់ព័ន្ធទាំងអស់

កោតសរសើរ និងដឹងគុណចំពោះការគាំទ្រពីគណៈកម្មការទ្រទ្រង់សាលារៀន ព្រះសង្ឃ និងសប្បុរសជនផ្សេងទៀតដោយជូនជាលិខិតថ្លែងអំណរគុណ ឬសរសេរឈ្មោះរបស់អ្នកគាំទ្រនៅលើជញ្ជាំងសាលា ឬកន្លែងលាងសម្អាតដៃជាក្រុម។





សេចក្តីសន្និដ្ឋាន

# ផែនការបន្ទាប់

បន្ទាប់ពីបានរៀនជាមួយមន្ត្រីថ្នាក់ខេត្ត ស្រុក និងថ្នាក់ជាតិ ជាពិសេសនាយកដ្ឋានសុខភាពសិក្សា ស្តីពីកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន ក្នុងនាមជាជនបង្គោលត្រូវដឹកនាំ បណ្តុះបណ្តាលនិងចែករំលែកមេរៀន ដើម្បីពង្រីកវិសាលភាពដល់គោលដៅ។ នេះត្រូវបានទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផងដែរ។ មន្ត្រីជំនាញនៅនាយកដ្ឋានសុខភាពសិក្សាបានធ្វើគម្រោងស្នើសុំមូលនិធិបន្ថែមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយជោគជ័យលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធកម្មវិធីទឹកស្អាតនិងអនាម័យ ចាប់តាំងពីឆ្នាំសិក្សា ២០១៥/២០១៦មក ហើយការផ្តល់ មូលនិធិទៅសាលារៀននឹងត្រូវបានបញ្ជាក់ជារៀងរាល់ឆ្នាំសិក្សា ។

មន្ទីរអប់រំ យុវជន និងកីឡាថ្នាក់ខេត្ត និងការិយាល័យអយក ក្រុង/ស្រុក ដើរតួសំខាន់ក្នុងការប្រែក្លាយ គោលនយោបាយជាតិទៅជាសកម្មភាពជាក់ស្តែងនៅតាមសាលារៀននីមួយៗ ។ មន្ទីរអប់រំយុវជន និងកីឡាខេត្តសម្របសម្រួលដំណើរការអនុវត្តនិងពង្រីកបន្ថែដោយការតម្រង់ទិសដល់មន្ត្រីថ្នាក់ស្រុក។ ការទំនាក់ទំនងការណែនាំជាយុទ្ធសាស្ត្រច្បាស់លាស់ ការប្រើប្រាស់រចនាសម្ព័ន្ធដែលមានស្រាប់សម្រាប់ការប្រជុំ និងពិនិត្យតាមដានការជំរុញឱ្យមានផែនការយុទ្ធសាស្ត្រ ការស្វែងរកការគាំទ្រមតិជាមួយអជ្ញាធរមូលដ្ឋាន និងការកសាងសមត្ថភាពរបស់មន្ត្រីថ្នាក់ស្រុក និងប្រធានកម្រង គឺជាមូលដ្ឋានគ្រឹះសម្រាប់ការពង្រីកគម្រោងប្រកបដោយជោគជ័យ។

ចំពោះសាលារៀន ជាពិសេសសាលារៀនដែលមានបញ្ហាប្រឈម គឺការិយាល័យអប់រំ យុវជន និងកីឡាស្រុកបានដឹកនាំគាំទ្រតាមរយៈប្រធានកម្រងក្នុងការផ្តល់គំនិតបំផុសយ៉ាងច្បាស់លាស់នូវអ្វីដែលសាលារៀនអាចសម្រេចបាន និងរបៀបដោះស្រាយបញ្ហាផ្សេងៗ ផ្តោតលើការកៀរគរធនធាន ការសាងសាងសង់បរិក្ខារអនាម័យនិងការអនុវត្ត។

ដូចដែលបានឃើញបទពិសោធន៍នៅក្នុងខេត្តកំពត គឺជាខេត្ត ដែលបានចូលរួមអនុវត្តគោលនយោបាយដ៏មានប្រសិទ្ធភាព និងទទួលខុសត្រូវក្នុងការកែលម្អកម្មវិធីទឹកស្អាតនិងអនាម័យ តាមរយៈការទំនាក់ទំនងនិងការស្វែងរកការគាំទ្រមតិពីអភិបាលខេត្ត និងអភិបាលស្រុក។ តាមរយៈទស្សនៈកិច្ចសិក្សាអភិបាលស្រុក ក្រុមប្រឹក្សាស្រុក មេឃុំ និងក្រុមប្រឹក្សាឃុំបានដឹងអំពីអ្វីដែលចាំបាច់និងអាចធ្វើទៅបាន។





## ដូច្នេះ ផែនការបន្ទាប់សម្រាប់ខេត្តកំពតគឺៈ

ពង្រីកគម្រោងទៅសាលារៀនដែលមានឆន្ទៈនិងអាចអនុវត្តសកម្មភាពនេះក្នុងគោលបំណងឱ្យសាលារៀនទាំងអស់នៅទូទាំងខេត្តមានបរិក្ខារអនាម័យដែលមានដំណើរការ និងគ្រប់គ្រាន់សម្រាប់សិស្សអនុវត្តទម្លាប់អនាម័យល្អ។

ពង្រឹងគុណភាពអនុវត្តដោយធានាថាសកម្មភាពអនាម័យជាក្រុមប្រចាំថ្ងៃមាននិរន្តរភាពដែលហេដ្ឋារចនាសម្ព័ន្ធអនាម័យត្រូវបានថែទាំ និងប្រើប្រាស់ ហើយនាយកសាលា នាយិកាសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សបន្តអនុវត្តទំនួលខុសត្រូវរៀងៗខ្លួន ។

ប្រើគោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមា ស្តីពីទឹកស្អាតនិងអនាម័យតាមសាលារៀនជាក្របខ័ណ្ឌសម្រាប់ធ្វើផែនការកែលម្អនិងតាមដានវឌ្ឍនភាព។ កម្រងសំណួរពិនិត្យតាមដានលក្ខខណ្ឌអប្បបរមាស្តីពីទឹកស្អាតនិងអនាម័យនឹងជួយដល់សាលារៀននិងថ្នាក់ក្រោមជាតិក្នុងការអនុវត្តនិងគ្រប់គ្រងកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀនព្រោះវាផ្តល់នូវទិន្នន័យចាំបាច់ដើម្បីសិក្សាពីស្ថានភាពទឹកស្អាតនិងអនាម័យរបស់សាលារៀន និងប្រភពធនធានដែលអាចរកបានដើម្បីធ្វើឱ្យប្រសើរឡើង។ គោលបំណងគឺដើម្បីឱ្យសាលារៀនទាំងអស់ឈានដល់យ៉ាងហោចណាស់ផ្កាយ១ និងឈានដល់ផ្កាយ៣បន្តិចម្តងៗ ។






## ខេត្តកំពត

អ្នកចងក្រងឯកសារ សង្ឃឹមថារបកគំហើញក្នុងការសិក្សានេះក៏នឹងជួយដល់ខេត្តផ្សេងដទៃទៀតនៃប្រទេសកម្ពុជា  ដើម្បីរៀបចំផែនការជាមុន និងចាត់វិធានផែនការបន្ត ដើម្បីសម្រេចឱ្យបានបាននូវកម្មវិធីទឹកស្អាតនិងអនាម័យសម្រាប់សិស្សានុសិស្សនៅក្នុងសាលារៀនរបស់គេ។ នៅក្នុងគោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមាស្តីពីទឹកស្អាតនិងអនាម័យតាមសាលារៀន មានកត្តាជោគជ័យសំខាន់ៗចំនួន៦ដែលបានកំណត់បង្ហាញនៅក្នុងខេត្តកំពតអាចជួយ មន្ទីរអប់រំ យុវជន និងកីឡាខេត្តដើម្បីកំណត់ពីគម្លាតក្នុងការគ្រប់គ្រងកម្មវិធីទឹកស្អាតនិងអនាម័យក្នុងសាលារៀននិងយុទ្ធសាស្រ្តសម្រាប់ដោះស្រាយបញ្ហាទាំងនោះ។

## ឯកសារយោង


- អង្គការសុខភាពពិភពលោកឬ អង្គការមូលនិធិសហប្រជាជាតិសម្រាប់កុមារបានចូលរួមពិនិត្យតាមដានគម្រោង ( ២០១៧ )-ទំហំនៃការសិក្សា៖ រៀបចំសម្រាប់របាយការណ៍គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពស្តីពីទឹកស្អាតនិងអនាម័យតាមសាលារៀននៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក
- ក្រសួងអភិវឌ្ឍន៍ជនបទ ( ២០១១ )៖ ផែនការយុទ្ធសាស្ត្រជាតិស្តីពីទឹកស្អាតនិងអនាម័យជនបទ ២០១១-២០១៥
- រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ( ២០១៣ )៖ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ២០១៤-២០១៨
- Duijster ( ២០១៧ )៖ គម្រោងអនាម័យគំរូតាមសាលារៀនជាកម្មវិធីមួយស្តីពីទឹកស្អាតនិងអនាម័យតាមសាលារៀនដើម្បីកែលម្អសុខភាពសិស្ស លទ្ធផលពីការសិក្សានៅប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ឡាវ និងសុខភាពសាធារណៈ: BMC


## ការបោះពុម្ព


**Published by the**
Deutsche Gesellschaft für
Internationale Zusammenarbeit (GIZ) GmbH

Registered offices
Bonn and Eschborn, Germany

Fit for School
11/F PDCP Bank Centre
cor. V.A. Rufino and L.P. Leviste Streets
Salcedo Village, Makati City 1227, Philippines
www.giz.de
www.fitforschool.international

**As at**
June 2018

**Design and layout**
Christine Lüdke, malzwei, Berlin, Germany

**Photo credits**
Mr. Seng Thy, (c) GIZ

GIZ implements programs and projects for sustainable development on behalf of the Federal Ministry for Economic Cooperation and Development (BMZ). The Regional Fit for School Program is realized in the Philippines, Indonesia, Cambodia and Lao PDR in partnership with the Southeast Asian Ministers of Education Organization Regional Centre for Educational Innovation and Technology (SEAMEO INNOTECH).

For more Information on GIZ Fit for School please contact
Nicole Siegmund, nicole.siegmund@giz.de

GIZ Fit for School is grateful to the MoEYS School Health Department, the Ministry of Health (MoH), and to the many people who contributed both content and their knowledge and insights to the final publication:

H.E. Kim Sethany, H.E. Put Samith, Dr. Chhaykim Sotheavy, Dr. Yung Kunthearith, Kao Rith, Pring Sarom, Kamsan Chay, Chum Phirun, Sok Vande, Seang Soleak, Seng Thy, Nicole Siegmund, Hiyas Clamor-Torneo, Ralf Panse, Piata Mendova, Alexander Winkscha, Marcel Siewert-Freundel, Thavy Rin, Sreypov Yuth, Synat Net, Sobin Mao, Bopha Khan, Theareach, and all the staff of province and district offices of education, of the featured schools, as well as their principals, teachers, students and their parents.



Disclaimer:
The publication is distributed free of charge and commercial reproduction is prohibited. GIZ encourages the distribution in the school health community; photocopying of the report and part of it for personal and educational purposes is allowed with recognition of the source. Requests for reprint and other inquiries should be directed to GIZ Fit for School, Manila, Philippines.

# ប្រភពឯកសារបន្ថែម

សូមស្វែងរកឯកសារបន្ថែម ស្តីពីការអនុវត្តកម្មវិធីទឹកស្អាតនិងអនាម័យនៅតាមសាលារៀននៅក្នុងវេបសាយ
→ www.fitforschool.international
ឬអ្នកអាចទាក់ទងផ្ទាល់ទៅនាយកដ្ឋានសុខភាពសិក្សានៅរាជធានីភ្នំពេញ។



### គោលការណ៍នាំអនុវត្តលក្ខខណ្ឌអប្បបរមាស្តីពីទឹកស្អាតនិងអនាម័យតាមសាលារៀន

ឯកសារនេះ ណែនាំពីជំហាននិងសកម្មភាពសាមញ្ញ ទាក់ទងនឹងការលើកកម្ពស់កម្មវិធីទឹកស្អាតនិងអនាម័យ ដែលត្រូវអនុវត្តផ្ទាល់ដោយ សាលារៀន ដើម្បីកាត់បន្ថយជំងឺឆ្លងពិសេសជំងឺរាគរូស ជំងឺផ្លូវដង្ហើម និងកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភ។




### គម្រោងអនាម័យគំរូតាមសាលារៀន - សៀវភៅណែនាំ ស្តីពីការបរិក្ខារលាងសម្អាតដៃជាក្រុម

សៀវភៅនេះណែនាំជាភាសាខ្មែរនិងអង់គ្លេស ស្តីពីបរិក្ខារលាងសម្អាតដៃជាក្រុមដែលចំណាយថវិកាខុសៗគ្នា។ បរិក្ខារទាំងនេះសាលារៀននិងសហគមន៍នៅប្រទេសកម្ពុជាបានរចនានិងសាងសង់ដោយខ្លួនឯង ។




### គម្រោងអនាម័យគំរូតាមសាលារៀន - សៀវភៅណែនាំសម្រាប់សាលារៀន និងសហគមន៍

សៀវភៅ "ណែនាំសម្រាប់សាលារៀន និងសហគមន៍" បានរៀបរៀងឡើងដោយនាយកដ្ឋានសុខភាពសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានការពារសុខភាពនៃក្រសួង សុខាភិបាល នាយកដ្ឋានថែទាំសុខភាពជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ និងសហការជាមួយ អង្គការ GIZ។ ឯកសារនេះ ជាឧបករណ៍ជំនួយស្មារតីដ៏មានសារៈសំខាន់ចំពោះអ្នកពាក់ព័ន្ធទាំងអស់ដែលមានបំណងអនុវត្តគម្រោងអនាម័យគំរូតាមសាលារៀននៅក្នុងសាលារៀនរបស់ខ្លួន។




### គម្រោងអនាម័យគំរូតាមសាលារៀន - សៀវភៅណែនាំ ស្តីពីការប្រើប្រាស់និងថែទាំសម្រាប់កម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន

សៀវភៅនេះ ណែនាំសាលារៀនពីការសម្អាត និងថែទាំហេដ្ឋារចនាសម្ព័ន្ធនិងសម្ភារបរិក្ខារទឹកស្អាត និងអនាម័យ ដើម្បីឱ្យប្រាកដថា មានការប្រើប្រាស់ និងដំណើរការជាប្រចាំ។




### WASHaLOT - សៀវភៅណែនាំស្តីពីការដំឡើងបរិក្ខារលាងសម្អាតដៃ

ទម្លាប់ដែលសាមញ្ញ នៃអនាម័យលាងសម្អាតដៃនឹងសាប៊ូ និងដុសសម្អាតធ្មេញបានរួមចំណែកយ៉ាងសំខាន់ដល់សុខភាព និងសុខុមាលភាពរបស់កុមារ ដែលគួរតែជាផ្នែកមួយនៃការអប់រំរបស់ពួកគេ។ គំនិតនៃការបង្រៀនអំពីការលាងសម្អាតដៃ និងដុសសម្អាតធ្មេញនៅក្នុងសាលារៀនមានរយៈ ពេលជាច្រើនទសវត្សមកហើយតែការអនុវត្តជាក់ស្តែងនៃសកម្មភាពទាំងនេះត្រូវបានរារាំង ដោយសារកុមារចំណាយពេលឈរតម្រង់ជួររង់ចាំយូរ។




### គម្រោងអនាម័យគំរូតាមសាលារៀន - សៀវភៅណែនាំ ស្តីពីការថែទាំបង្គន់អនាម័យសម្រាប់សាលារៀន និងសហគមន៍

សៀវភៅណែនាំ ជាឧបករណ៍មួយដើម្បីផ្តល់ការណែនាំ និងបំផុសគំនិតដល់សាលារៀនក្នុងការកែលម្អបង្គន់អនាម័យដោយផ្តោតលើប្រធានបទងាយៗ លើការសម្អាតបង្គន់ និងចំណុចដែលមានលក្ខណៈស្មុកស្មាញដូចជាការដោះស្រាយបញ្ហាទឹកសំណល់ជាដើម។




### ការពង្រីកបរិក្ខារលាងសម្អាតដៃជាក្រុមតាមសាលារៀន

ការបង្ហាញពីបរិក្ខារលាងសម្អាតដៃជាក្រុមនៅជុំវិញពិភពលោក ( UNICEF - BMZ - GIZ ) រួមមានឧទាហរណ៍មកពីប្រទេសមួយចំនួនដូចជា៖ ប្រទេសអាហ្វហ្គានីស្ថាន កម្ពុជា ហ្វីជី ឥណ្ឌា ឥណ្ឌូនេស៊ី គីរីបាទី ឡាវ លីបារៀ ម៉ាលី ណាយជើរៀ ហ្វីលីពីន តាន់សានា និងសាមបៀ។ បរិក្ខារទាំងនេះសាងសង់ឡើងខុសគ្នាទៅតាមកាលៈទេសៈ តម្រូវការ និងធនធានរបស់សាលារៀន និងសហគមន៍នៅក្នុងប្រទេសនីមួយៗ។

ដៃគូសហការ

german cooperation
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ៖

giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

SEAMEO INNOTECH



www.fitforschool.international